# ការបញ្ឈប់រថយន្តអាចជាព្រឹត្តិការណ៍មួយដ៏តានតឹង

គឺមានមូលហេតុច្រើនយ៉ាង ថាហេតុអ្វីបានជាអ្នកត្រូវប៉ូលិសបញ្ឈប់:

- អ្នកប្រហែលបានប្រព្រឹត្តរំលោភនឹងច្បាប់ចរាចរ
- អ្នកប្រហែលមានលក្ខណៈដូចនឹងជនគេសង្ស័យ
- អ្នកប្រហែលជួយបញ្ជាក់ពីឧក្រិដ្ឋកម្ម
- ភ្នាក់ងារប៉ូលិសអាចគិតថា អ្នកត្រូវការជំនួយ ឬម៉្យាងវិញកំពុងស្ថិតក្នុងភាពគ្រោះថ្នាក់

បើអ្នកត្រូវបានបញ្ឈប់ដោយប៉ូលិសនៅពេលបើកបរ អ្នកប្រហែលមានអារម្មណ៍ច្របូកច្របល់ ខ្វាយខ្វល់ ឬជួនកាលខឹងផង។ ទាំងនេះគឺជាអារម្មណ៍ធម្មតាទេ ប៉ុន្តែត្រូវចាំថា ការបញ្ឈប់ដោយប៉ូលិសគឺក៏តានតឹងសំរាប់ភ្នាក់ងារប៉ូលិសដែរ។ ជាទូទៅក្នុងរដ្ឋភ្នាក់ងារប៉ូលិសជាច្រើនត្រូវទទួលរបួស ឬត្រូវគេសម្លាប់ នៅពេលធ្វើ "ទម្រង់ការ" បញ្ឈប់រថយន្តធម្មតា។

នៅក្នុងសៀវភៅស្តើងនេះ យើងផ្តល់ជូននូវតម្រុយជាទូទៅខ្លះនិងការទូន្មានសំរាប់អ្នកបើកបរ ដែលអាចជួយឲ្យការបញ្ឈប់រថយន្តមានសុវត្ថិភាព និងមិនសូវមានភាពតានតឹងសំរាប់អ្នក និងភ្នាក់ងារប៉ូលិស។

www.tacomapolice.org

# គោលបំណង:

*ដើម្បីបង្កើតបរិយាកាសមានសុវត្ថិភាពនិងផុតពីគ្រោះថ្នាក់ ដែលជាកន្លែងដើម្បីរស់នៅ, ធ្វើការ, និងទស្សនា គឺដោយការរួមដៃគ្នាធ្វើការជាមួយនឹងសហគមន៍, ការអនុវត្តន៍ច្បាប់ដោយយុត្តិធម៌និងគ្មានភាពលំអៀង, ការថែរក្សាភាពស្ងប់ស្ងាត់និងរបៀបរៀបរយនៅក្នុងមូលដ្ឋានរបស់យើង, ហើយនិងការរក្សាសន្តិសុខនៃការធានារ៉ាប់រងដោយស្របច្បាប់របស់យើង។*



Tacoma

Tacoma Police Department
3701 S. Pine Street
Tacoma, Washington 98409
(253) 591-5900

www.tacomapolice.org

ការយល់ដឹងពីការបញ្ឈប់ចរាចររបស់ប៉ូលិស

# TRAFFICSTOP

## (ការបញ្ឈប់ចរាចរ)







ក្រុងTacoma, រដ្ឋWashington

ក្រសួងប៉ូលិសក្រុងTacoma



# ហេតុដូចម្តេចបានជាប៉ូលិស បញ្ឈប់ប្រជាជន?

គុណភាពនៃជីវិតទូទាំងក្រុង Tacoma គឺកុះករ ដោយយោងលើចលនាសេរីនៃប្រជាជននិងរថយន្ត។ ក្រសួងប៉ូលិសក្រុង Tacoma មានការបែងចែក ច្រើនជាងគេនៃការទទួលខុសត្រូវសំរាប់ការសំរេច និងការថែរក្សាកិរិតនៃបទបញ្ជាចាំបាច់ដើម្បីធ្វើឲ្យចលនាសេរីនេះអាចមានដំណើរការ បាន។

គោលបំណងសំខាន់ជាងក្នុងចលនានៃប្រជាជននិងរថយន្តគឺជាកង្វល់មួយសំរាប់សុវត្ថិភាពសាធារណៈជននិងភ្នាក់ងារប៉ូលិស។




ការអនុវត្តន៍លើចរាចរគឺជាកាតព្វកិច្ចមួយក្នុងចំណោមកាតព្វកិច្ចច្រើនជាងគេដែលបានធ្វើដោយភ្នាក់ងារប៉ូលិសក្រុង Tacoma, ប៉ុន្តែគឺសំរាប់តែពលរដ្ឋខ្លះប៉ុណ្ណោះ វាក៏អាចជាបទពិសោធន៏នៃការភ័យខ្លាចក្នុងអារម្មណ៍ដែរ។ នៅក្នុងករណីជាច្រើននេះគឺជាទំនាក់ទំនងរបស់ជនម្នាក់ប៉ុណ្ណោះដែលអាចមានជាមួយនឹងភ្នាក់ងារអាជ្ញាធរផ្នែកផ្លូវច្បាប់។

ភ្នាក់ងារនៃក្រសួងប៉ូលិសក្រុង Tacoma គឺដឹងអំពីលក្ខណៈទាំងនេះ និងមានបំណងធ្វើការសាកបង្រៀនពេលបញ្ឈប់រថយន្តនិមួយៗនិងការទាក់ទំនងអប់រំ។



## បើសិនជាអ្នកត្រូវប៉ូលិសបញ្ឈប់

- បើកចេញក្រៅទៅចញ្ចើមថ្នល់ខាងស្តាំ ហើយចត រថយន្តរបស់អ្នកឲ្យឆ្ងាយបំផុតពីឡេនបើកបរ។
- ពន្លត់ម៉ាស៊ីនរថយន្ត,បិទវិទ្យុ, ថេបឬ CD ចំរៀង, ឬម៉ាស៊ីនឯទៀតដែលប្រហែលជាមានសំឡេងរំខាន ដល់ការនិយាយគ្នាជាមួយនឹងភ្នាក់ងារប៉ូលិស។
- បើកភ្លើងស៊ីញ៉ូភ្លឹបភ្លែតរបស់រថយន្តអ្នក(ភ្លើងអាសន្ន) និងនៅពេលយប់ បើកភ្លើងក្នុងរថយន្តរបស់អ្នក, ដើម្បីឲ្យភ្នាក់ងារប៉ូលិសអាចឃើញនូវអ្វីៗស្ថិតនៅ ក្នុងលក្ខណៈរៀបរយ។
- រត់វកញ្ចក់រថយន្តរបស់អ្នកចុះ ដើម្បីឲ្យអ្នកនិងភ្នាក់ងារប៉ូលិសអាចនិយាយគ្នាបាន។ នៅឲ្យស្ងៀម និងបើសិនជាមានអ្នកជិះជាមួយនៅក្នុងរថយន្ត ប្រាប់ទៅពួកគេនៅស្ងៀមផងដែរ។ ទុកខ្សែក្រវាត់របស់អ្នកឲ្យជាក់នៅជាប់ និងប្រាប់អ្នកជិះទាំងអស់ ទុកខ្សែក្រវ៉ាត់ឲ្យជាក់នៅជាប់ដូចអ្នកដែរ។
- អង្គុយរង់ចាំក្នុងរថយន្តរបស់អ្នកនិងកុំចេញលើកលែងតែភ្នាក់ងារប៉ូលិសប្រាប់ឲ្យអ្នកចេញពីរថយន្ត។
- ដាក់ដៃរបស់អ្នកឲ្យនៅស្រឡះលើចង្កូតរថយន្ត របៀបដាក់ជាទ្រនិចនាឡិកត្រង់ “ម៉ោង 10” និង “ម៉ោង ២”។ ប្រាប់អ្នកជិះទាំងអស់ឲ្យដាក់ដៃរបស់ពួកគេមើលឃើញដូចជាដាក់លើភ្លៅ។
- ចូរកុំធ្វើចលនាអ្វីប្រញិបប្រញាប់ ដែលអាចនាំឲ្យភ្នាក់ងារប៉ូលិសគិតថាអ្នកលាក់ឬរុករករបស់អ្វី។



# បើរថយន្តអ្នកត្រូវប៉ូលិសបញ្ឈប់ ចំណុចសំខាន់ គឺសហការណ៍។

ពត៌មានខាងក្រោមនេះគឺបានផ្តល់ជូនដើម្បីជួយអ្នក ឲ្យយល់ពីមុខងាររបស់អ្នកនៅពេលប៉ូលិសបញ្ឈប់។

- ចូរឲ្យប្រាកដថា អ្នកមានអត្តសញ្ញាណប័ណ្ណត្រឹមត្រូវ។ នៅក្នុងរដ្ឋ Washington អ្នកត្រូវតែមានប័ណ្ណបើកបរស្របច្បាប់, ភស្តុតាងនៃលិខិតចុះបញ្ជីរថយន្ត និងភស្តុតាងការធានារថយន្ត។ បើភ្នាក់ងារប៉ូលិសសួរអ្នករកសំបុត្រទាំងនេះ ចូរប្រាប់ទៅភ្នាក់ងារប៉ូលិសថាវានៅឯណា និងលូកយកវាដោយយឺតៗ ជាថ្មីម្តងទៀតចូរជៀសវាងកុំធ្វើដោយប្រញិបប្រញាប់។
- ឆ្លើយទៅនឹងសំណួររបស់ភ្នាក់ងារប៉ូលិសឲ្យពេញលេញ និងឲ្យបានច្បាស់ ហើយបើមានអ្វីមួយដែលអ្នកមិនយល់ សួរទៅភ្នាក់ងារប៉ូលិសដោយគួរសមឲ្យគាត់ និយាយឡើងវិញ។
- ចូរកុំស្ងន់ បើសិនជាមានរថយន្តតម្រួតផ្សេងមួយទៀតបើកចូលមក។ នេះគឺគេធ្វើសំរាប់ការធានាពីសុវត្ថិភាពរបស់ភ្នាក់ងារប៉ូលិសគ្នាគេប៉ុណ្ណោះហើយនេះគឺជារឿងធម្មតាទេ។
- បើសិនជាមិនច្បាស់ពីការពិន័យប្រាក់ ឬដីកាពិន័យ (សំប៉ុតផាក) ចូរសួរភ្នាក់ងារប៉ូលិសក្នុងភាពគួរសមឲ្យពន្យល់។ ជៀសវាងកុំឲ្យទៅជាការជជែកតវ៉ា។ បើសិនជាអ្នកមិនយល់ស្របជាមួយនឹងដីកាពិន័យ (សំប៉ុតផាក) អ្នកនឹងមានឱកាសធ្វើការតវ៉ាលើដីកាពិន័យនេះនៅឯតុលាការ។
- ចូរចាំថា ការបញ្ឈប់រថយន្តនិមួយៗគឺដូចតែគ្នា ហើយភ្នាក់ងារប៉ូលិសនឹងធ្វើសកម្មភាព ហើយនិងឆ្លើយតបតំរូវឲ្យស្របទៅតាមហេតុការណ៍។

ក្នុងប្រយោជន៏នៃសុវត្ថិភាពសាធារណៈជន ការធ្វើសហការណ៍ជាមួយនឹងប៉ូលិសគឺជាការទទួលខុសត្រូវរបស់សហគមន៏។